**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. [illegible] MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី : ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin) ជូនអង្គការក្រៅរដ្ឋាភិបាល (NGOs)

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- ក្នុងគោលបំណងបង្កើនសន្ទុះនាំចេញផលិតផលក្នុងស្រុក និង ដើម្បីជួយសំរួលបែបបទនាំចេញផលិតផលសិប្បកម្មផ្សេងៗ ធ្វើអំពីសូត្រ , អំបោះ , ដែក , ថ្មៅ , កំប្លោក , ស្លឹកត្នោត , គ្រឿងចម្លាក់សម័យទំនើប , វត្ថុប្រើប្រាស់បន្ទាប់បន្សំ ។ល។ ឱ្យបានឆាប់រហ័ស

## សំរេច

**ប្រការ ១ :** ដើម្បីអោយអង្គការក្រៅរដ្ឋាភិបាលមានសិទ្ធ ទទួលបានវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញពីក្រសួងពាណិជ្ជកម្ម សំរាប់នាំទំនិញសិប្បកម្មរបស់ខ្លួនទៅបរទេសបាន អង្គការក្រៅរដ្ឋាភិបាល (NGOs) ត្រូវបង្កើតក្រុមហ៊ុនមួយជាលក្ខណៈសហគ្រាសឯកបុគ្គល ទទួលខុសត្រូវមានកំរិត ដោយប្រើប្រាស់ដើមទុនបានមកពីអង្គការក្រៅរដ្ឋាភិបាល រីឯប្រាក់ចំណេញត្រូវបានបង្វិលទៅអង្គការក្រៅរដ្ឋាភិបាលនោះទាំងស្រុងវិញ ។

**<u>ប្រការ</u> ២ :** បន្ទាប់ពីបានបង្កើតក្រុមហ៊ុននៅនាយកដ្ឋាននិតិកម្មរួចហើយ អង្គការក្រៅរដ្ឋាភិបាលត្រូវចុះបញ្ជីនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដើម្បីទទួលបានសិទ្ធនាំចេញតាមរយៈប្រព័ន្ធ MFN/GSP ( លើកលែងផលិតផលជាប់កូតា ) ។

**<u>ប្រការ</u> ៣ :** ការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញនេះ (C/O) ត្រូវបានលើកទឹកចិត្តជូនដោយមិនមានបង់កំរៃ ឬ សោហ៊ុយរដ្ឋបាលអ្វីឡើយ ក្នុងករណីផលិតផលនាំចេញមិនជាប់កូតា ។

**<u>ប្រការ</u> ៤ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម , ប្រធាននាយកដ្ឋានកាំកុងត្រូល , ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u> :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- អង្គការក្រៅរដ្ឋាភិបាល
- ឯកសារ-កាលប្បវត្តិ